00907355



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 05 / 2013
ម៉ោង (Time/Heure): 14:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Première instance

## កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី

## សាធារណៈ

## សំណុំរឿងលេខ ០០២/១៩-កញ្ញា-២០០៧/អវតក/អជសង

## ថ្ងៃ ចន្ទ ទី ២៨ ខែ មករា ឆ្នាំ ២០១៣

## សវនាការលើអង្គសេចក្តី- ថ្ងៃទី ១៥២

រៀបចំដោយ: សែ កុលវុឌ្ឍី និង Roger PHILLIPS

| កំណត់ហេតុអ្នកចូលរួមក្នុងបន្ទប់សវនាការ |
|---|
| ចំពោះមុខ៖ ចៅក្រម និល ណុន (ប្រធាន), ចៅក្រម Silvia CARTWRIGHT, ចៅក្រម យ៉ា សុខន, ចៅក្រម Jean-Marc LAVERGNE, ចៅក្រម យូរ ឧត្តរា |
| ចៅក្រមបម្រុង៖ ចៅក្រម ធូ មណី, ចៅក្រម Claudia FENZ |
| ក្រឡាបញ្ជី៖ លោកស្រី សែ កុលវុឌ្ឍី, លោកស្រី Faiza ZOUAKRI , លោក ដាវ អានសាន, លោក Roger PHILLIPS |
| ការិយាល័យសហព្រះរាជអាជ្ញា៖ លោក សេង ប៊ុនឃាង, លោក Dale Lysak |
| ជនជាប់ចោទ៖ អៀង សារី (ពីបន្ទប់ឃុំខ្លួននៅពីខាងក្រោមសាលសវនាការ), ខៀវ សំផន និង នួន ជា |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ នួន ជា៖ លោក សុន អរុណ, លោក Victor KOPPE |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ អៀង សារី៖ លោក អាង ឧត្តម, លោក Michael G. Karnavas |
| ក្រុមមេធាវីការពារឲ្យជនជាប់ចោទ ខៀវ សំផន៖ លោក គង់ សំអុន, លោកស្រី Anta GUISSE |

| |
|---|
| មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី៖ លោកស្រី Elisabeth SIMONNEAU-FORT, លោក វ៉ែន ពៅ, លោក ពេជ អង្គ, លោកស្រី ស៊ិន សុវ៉ន, លោក ហុង គីមសួន, លោក សំ សុគង់, លោកស្រី ទី ស្រីនណា, លោក ឡោ ជុនធី, លោកស្រី Christine MARTINEAU. |
| សាក្សី៖ លោក Al ROCKOFF (TCW-565) |
| មន្ត្រីតុលាការ/ផ្នែកគ្រប់គ្រងតុលាការ៖ លោក អ៊ុច អារុណ, លោកស្រី សួ សុទ្ធាវី |
| ផ្សេងៗ៖ កញ្ញា Elburg VAN BOETZELAER |

**ពេលវេលាទូទៅរបស់តុលាការ៖**

| | | |
|---|---|---|
| ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣ | ចាប់ផ្ដើមម៉ោង៖ ០៩.២០ | បញ្ចប់ម៉ោង៖ ១៦.១០ |
| សម្រាកពេលព្រឹក | ចាប់ផ្ដើមម៉ោង៖ ១០.៤០ | បញ្ចប់ម៉ោង៖ ១១.០៥ |
| សម្រាកពេលថ្ងៃត្រង់ | ចាប់ផ្ដើមម៉ោង៖ ១២.០៥ | បញ្ចប់ម៉ោង៖ ១៣.៣០ |
| សម្រាកពេលល្ងាច | ចាប់ផ្ដើមម៉ោង៖ ១៤.៣៥ | បញ្ចប់ម៉ោង៖ ១៥.០៥ |
| ចំនួនម៉ោងសរុបរបស់តុលាការ៖ ០៤ ម៉ោង ៥០ នាទី | | |

**កិច្ចដំណើរការនីតិវិធី៖**

| ប្រភេទបញ្ហា | លើកឡើងដោយ | ម៉ោងចាប់ផ្ដើម | ម៉ោងបញ្ចប់ |
|---|---|---|---|
| ការលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការ | អង្គជំនុំជម្រះ | ០៩.២០ | ០៩.២១ |
| សំណើសុំចូលរួមសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ | អង្គជំនុំជម្រះ | ០៩.២១ | ០៩.២៣ |
| ការស្នើសុំពេលវេលាបន្ថែមរបស់ សហព្រះរាជអាជ្ញា | មេធាវីការពារក្ដី អៀង សារី<br>សហព្រះរាជអាជ្ញា<br>អង្គជំនុំជម្រះ | ០៩.២៣ | ០៩.៣០ |
| ការតាំងសំណួរទៅសាក្សី Al ROCKOFF (TCW-565) | អង្គជំនុំជម្រះ<br>សហព្រះរាជអាជ្ញា<br>មេធាវីតំណាងដើមបណ្ដឹងរដ្ឋប្បវេណី<br>អង្គជំនុំជម្រះ | ០៩.៣១<br>០៩.៣៨<br>១៤.០៩<br>១៥.០៣ | ០៩.៣៨<br>១៤.០៩<br>១៤.៣៤<br>១៦.០៥ |

| | | | |
|---|---|---|---|
| ការស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់នៅបន្ទប់សវនាការ | មេធាវីការពារក្តី ខៀវ សំផន | ១២.០១ | ១២.០៦ |
| សេចក្តីសម្រេចលើសំណើសបន្ថែមពេលវេលាក្នុងការសួរទៅសាក្សី | អង្គជំនុំជម្រះ | ១២.០៦ | ១២.០៧ |

**<u>សេចក្តីសង្ខេបនៃកិច្ចដំណើរការនីតិវិធីផ្សេងៗទៀត៖</u>**

**<u>ការលះបង់សិទ្ធិមានវត្តមានពីបន្ទប់សវនាការក្នុងអំឡុងពេលស្តាប់សក្ខីកម្មសាក្សី TCW-565</u>**

ជនជាប់ចោទ នួន ជា កំពុងតែសម្រាកព្យាបាលនៅមន្ទីរពេទ្យមិត្តភាពខ្មែរ-សូវៀត និងតាមរយៈមេធាវីការពារក្តីរបស់គាត់ បានដាក់លិខិតលះបង់សិទ្ធិមានវត្តមានក្នុងអំឡុងពេលនៃការស្តាប់សក្ខីកម្មសាក្សី TCW-565 ។ ផ្អែកទៅតាមរបាយការណ៍ពីមន្ទីរពេទ្យ បង្ហាញថាសុខភាពរបស់ជនជាប់ចោទ នួន ជា បានប្រសើរហើយ និងសង្ឃឹមថានឹងចេញពី មន្ទីរពេទ្យឆាប់ៗនេះ។ អង្គជំនុំជម្រះសម្រេចតាមការស្នើសុំដោយមានការព្រមព្រៀងពីជនជាប់ចោទ។

**<u>សំណើសុំលះបង់សិទ្ធិក្នុងការចូលរួមដំណើរការសវនាការដោយផ្ទាល់ពីបន្ទប់សវនាការ</u>**

ជនជាប់ចោទ អៀង សារី បានស្នើសុំចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការដោយមូលហេតុសុខភាព។ អង្គជំនុំជម្រះបានទទួលយកសំណើរបស់ អៀង សារី និងអនុញ្ញាតិឱ្យគាត់ចូលរួមដំណើរការសវនាការពីចំងាយសម្រាប់រយៈពេលពេញមួយថ្ងៃ។

**<u>សំណើសុំពេលវេលាបន្ថែមរបស់ សហព្រះរាជអាជ្ញា ក្នុងការតាំងសំណួរទៅសាក្សី TCW-565</u>**

សហព្រះរាជអាជ្ញាបានស្នើសុំពេលវេលាបន្ថែមមួយថ្ងៃកន្លះសម្រាប់តាំងសំណួរទៅសាក្សី ប៉ុន្តែមេធាវីការពារក្តី អៀង សារី បានជំទាស់ចំពោះការស្នើសុំនេះ ដោយបានលើកឡើងថា ការស្នើសុំនេះបានធ្វើឡើងយឺតពេល និងស្នើឱ្យអង្គជំនុំជម្រះប្រកាន់យកពេលវេលាដែលបានបែងចែករួចហើយនេះ។ អង្គជំនុំជម្រះសម្រេចថានឹងពិចារណាទៅតាមស្ថានភាពជាក់ស្តែង។

**<u>ការតាំងសំណួរទៅសាក្សី Al ROCKOFF (TCW-565)</u>**

អង្គជំនុំជម្រះបានតាំងសំណួរទៅសាក្សី អំពីប្រវត្តិសាវតាររបស់សាក្សី និងបានប្រាប់អំពីសិទ្ធិនិងករណីកិច្ចរបស់សាក្សី។ បន្ទាប់មកសហព្រះរាជអាជ្ញាបានចាប់ផ្តើមតាំងសំណួរទៅសាក្សី ហើយបន្តមកមេធាវីនាំមុខតំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីបានតាំងសំណួរទៅសាក្សី។

**សំណើសុំចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួននៅពីក្រោមសាលសវនាការ**

ជនជាប់ចោទ ខៀវ សំផន បានស្នើសុំតាមដានដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការ សម្រាប់សវនាការពេលរសៀលនេះ ដោយសារតែមូលហេតុសុខភាព។ អង្គជំនុំជម្រះបានសម្រេចតាមការស្នើសុំរបស់ ជនជាប់ចោទឱ្យចូលរួមដំណើរការសវនាការពីចំងាយ និងស្នើឱ្យដាក់លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ។

**សេចក្តីសម្រេចលើសំណើសុំបន្ថែមពេលវេលារបស់សហព្រះរាជអាជ្ញា**

អង្គជំនុំជម្រះបានសម្រេចទទួលយកសំណើរបស់សហព្រះរាជអាជ្ញា ដោយបន្ថែមពេលវេលាឱ្យសហព្រះរាជអាជ្ញា និងមេធាវីនាំមុខក្នុងការតាំងសំណួរទៅសាក្សី រហូតដល់សម្រាកពេលរសៀល។

**កំណត់ហេតុនៃកិច្ចដំណើរការនីតិវិធីតាមវិធាន ៨៧ (៣) វិធាននៃភស្តុតាង**

| TC No | OCIJ No | ERN | Title | Class | Note in Khmer | Note in English | Note in French |
|---|---|---|---|---|---|---|---|
| E3/117 | D108/43/1 | 00242308-00242314<br>00166772-00166775<br>00281432-00281435 | ឧបសម្ព័ន្ធ ១៖ Khieu Samphan Chairs NUFC Congress Session ចុះថ្ងៃទី ២៦ ខែកុម្ភៈ ឆ្នាំ ១៩៧៥<br>Annex 1: Khieu Samphan Chairs NUFC Congress Session dated 26 February 1975<br>Annex 1: Khieu Samphan Chairs NUFC Congress Session dated 26 February 1975 | P | 00242309 | 00166772 | 00281432 |
| E3/3208 | D313/1.2.11 | 00826501-00826518<br>00432391-00432514<br>00700293-00700298 | [Partial T.] សៀវភៅនិពន្ធដោយលោក Roland Neveu ក្រោមចំណងជើងថា "ការដួលរលំនៃទីក្រុងភ្នំពេញ"<br>Book by Roland Neveu entitled "The Fall of the Phnom Penh"<br>[Partial T.] Livre de Roland Neveu intitulé "The Fall of the Phnom Penh" | P | | 00432437, 00432444, 00432458, 00432453, 00432481, 00432482, 00432469, 00432470 | |
| E3/3986 | D366/7.1.416 | P 00000001-00000001 | International Photograph by Al ROCKOFF. | P | | | |
| E3/3342 | D313/1.2.6 | 00738378-00738423<br>00431115-00431418<br>00763798-00763839 | [Partial T.] សៀវភៅរៀបរៀងដោយ Jon SWAIN មានចំណងជើងថា៖ "River of Time"<br>Book by Jon SWAIN entitled "River of Time"<br>[Partial T.] Livre de Jon Swain intitulé "River of Time" | P | 00738393-00738394 | 00431267-00431268 | 00763811 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| E3/51 | D366/ 7.1.27 8 | S 00644696-00644740 S 00003276-00003284 00597828-00597853 | របាយការណ៍ពីបណ្ដាញសារព័ត៌មានអន្តរជាតិស្ដីពីការដួលរលំនៅទីក្រុងភ្នំពេញ International Media report on the fall of Phnom Penh International Media report on the fall of Phnom Penh | P | S0064470 6- S0064470 7, S0064470 9, S0064471 0, S0064471 7 | S0003278 | 00597834, 00597835, 00597840 |
| E3/2355 R | D108/ 32.2R | V00172454 - V00172454 (EN) | Pol Pot: The Killing Embrece | P | 25.22-26.05; 25.41 | 25.22-26.05; 25.41 | 25.22-26.05; 25.41 |
| E3/3987 | D365/ 1.1.22 | 00656309-00656317 00444899-00444901 00664018-00664022 | ពត៌មានពីក្នុងប្រទេសកម្ពុជា Inside Cambodia Vu au Cambodge | P | 00656314 | 00444900 | 00664021 |
| E3/604 | D313/ 1.2.30 0 | 00632772-00632773 00419043-00419044 00599739-00599742 | បណ្ដាញសារព័ត៌មានរបស់ Bangkok Post ចុះថ្ងៃទី ២ ខែវិច្ឆិកា ឆ្នាំ១៩៧៥ មានចំនងជើងថា៖ ការទទួលស្គាល់ថាមានការប្រហារជីវិត Media article entitled: "Executions Admitted", Bangkok Post, 2 November 1975 Article de Bangkok Post intitulé: "Executions Admitted", le 2 novembre 1975 | P | | | |
| E3/2348 R | D108/ 32.2R | V00172506 - V00172506 (FR) | Khmer Rouge History of Genocide | P | 27:10-27:59 | 27:10-27:59 | 27:10-27:59 |
| E3/2694 | D199/ 26.2.1 99 | 00491363-00491364 00486889-00486889 00391442-00391442 | សារទូរលេខទាក់ទងនឹងការជ្រកកោនផ្នែកនយោបាយ Télégramme intitulé Asile politique Télégramme intitulé Asile politique | P | | | |
| E3/3988 | | | Photograph taken by Al Rockoff | P | | | |
| E3/3989 | | | Photograph taken by Al Rockoff | P | | | |
| E3/3990 | | | Photograph taken by Al Rockoff | P | | | |
| E3/3991 | | | Photograph taken by Al Rockoff | P | | | |
| E3/3992 | | | Photograph taken by Al Rockoff | P | | | |

| | | |
|---|---|---|
| E3/3993 | Photograph taken by Al Rockoff | P |
| E3/3994 | Photograph taken by Al Rockoff | P |

**ដីកា/សេចក្តីសម្រេចផ្ទាល់មាត់៖**

- អង្គជំនុំជម្រះសម្រេចឱ្យជនជាប់ចោទ អៀង សារី ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការសម្រាប់រយៈពេលពេញមួយថ្ងៃ និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- អង្គជំនុំជម្រះសម្រេចបន្តសវនាការដោយមិនមានវត្តមានជនជាប់ចោទ នួន ជា តាមការយល់ព្រមពីជនជាប់ចោទ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- អង្គជំនុំជម្រះសម្រេចឱ្យជនជាប់ចោទ ខៀវ សំផន ចូលរួមដំណើរការសវនាការពីបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការសម្រាប់សវនាការពេលរសៀល និងបង្គាប់ឱ្យផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍ (លិខិតលះបង់សិទ្ធិរបស់ជនជាប់ចោទ បានភ្ជាប់ជាឧបសម្ព័ន្ធទៅនឹងកំណត់ហេតុនេះ)។
- បង្គាប់ឱ្យអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ជូនសាក្សី Al ROCKOFF ត្រឡប់ទៅកាន់កន្លែងសម្រាក និងឱ្យនាំគាត់ត្រឡប់មកចូលរួមសវនាការវិញនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣។
- បង្គាប់ឱ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ អៀង សារី និង ខៀវ សំផន ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងវិញនិងបង្គាប់ឱ្យនាំខ្លួន ខៀវ សំផន មកកាន់បន្ទប់សវនាការ និង អៀង សារី មកត្រឹមបន្ទប់ឃុំខ្លួននៅខាងក្រោមសាលសវនាការនៅថ្ងៃទី ២៩ ខែ មករា ឆ្នាំ ២០១៣។

**កាលបរិច្ឆេទបន្តសវនាការ៖**

សវនាការនឹងបន្តនៅថ្ងៃ អង្គារ៍ ទី ២៩ ខែ មករា ឆ្នាំ ២០១៣ វេលាម៉ោង ០៩.០០ ព្រឹក។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មករា ឆ្នាំ ២០១៣

ក្រឡាបញ្ជី ក្រឡាបញ្ជី

**សែ កុលវុឌ្ឍី** Roger PHILLIPS